

# សញ្ញាណទូទៅ និងច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងឧស្សាហកម្មនៅកម្ពុជា

## តើអ្នកដឹងទេថា...

ថ្វីត្បិតតែការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យឧស្សាហកម្ម បានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ក៏ប៉ុន្តែវាបានផ្តល់មកវិញនូវបញ្ហាប្រឈមយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងសុខុមាលភាពសង្គម ដោយការបញ្ចេញចោលនូវកាកសំណល់រឹងឧស្សាហកម្ម។

## តើកាកសំណល់រឹងឧស្សាហកម្មជាអ្វី ?

សំដៅទៅលើកាកសំណល់រឹងដែលបង្កើតដោយដំណើរការផលិតកម្ម ឬឧស្សាហកម្ម នឹងត្រូវបានបញ្ចេញចោលពីរោងចក្រ។



រក្សាសិទ្ធិ:Thomas Cristofoletti/Ruom. Copyright©2018 Royal Holloway, University of London

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ

- រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣៖ មាត្រា៥៩
- ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- អនុក្រឹត្យលេខ៣៦ ស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩
- សេចក្តីណែនាំលេខ០១១ របស់ក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងកាកសំណល់រឹងរបស់រោងចក្រ សហគ្រាស និងគ្រឹះស្ថាន (ខែមករា ឆ្នាំ២០០៣)
- សេចក្តីប្រកាសរួមលេខ៨០ របស់ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងសំរាមរឹងនៅខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា

## ហេតុអ្វីយើងគួរស្វែងយល់ និងយកចិត្តទុកដាក់ ?

- លើកកម្ពស់គុណភាពបរិស្ថាននិងសុខភាពពលរដ្ឋតាមរយៈការចូលរួមពីសាធារណៈជន ក្នុងការទប់ស្កាត់ កាត់បន្ថយ គ្រប់គ្រងការបំពុលបរិស្ថាន និងបង្ក្រាបរាល់សកម្មភាពដែលអាចប៉ះពាល់ដល់បរិស្ថាន។
- ចូលរួមអភិរក្ស និងអភិវឌ្ឍន៍បរិស្ថានប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។
- ជាគ្រឹះដ៏សំខាន់ក្នុងការសិក្សាស្វែងយល់អំពីប្រភពនៃបញ្ហា និងដំណោះស្រាយក្នុងការកាត់បន្ថយបញ្ហាកាកសំណល់ឧស្សាហកម្ម។
- លើកកម្ពស់នីតិរដ្ឋដោយសិក្សាយល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក៏ដូចជាបុគ្គលពាក់ព័ន្ធ ក្នុងការចូលរួមអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាដែលមានចែងដោយរាជរដ្ឋាភិបាល។



រក្សាសិទ្ធិ:Thomas Cristofoletti/Ruom. Copyright©2018 Royal Holloway, University of London

# តើយើងទាំងអស់គ្នាអាចចូលរួមកាត់បន្ថយបញ្ហាទាំងនេះដោយវិធីណាខ្លះ ?

ទី១៖ ទាមទារចាំបាច់នូវការចូលរួមដោយ ម្ចាស់សហគ្រាស ផ្ទាល់អាជ្ញាធរដែលស្ថិតក្រោម ក្រសួង ដែលពាក់ព័ន្ធ និង អ្នកផ្តល់សេវាសំរាម។

ទី២៖ ម្ចាស់សហគ្រាស មានតួនាទី នៅក្នុងការគ្រប់គ្រង សំណល់រឹងឧស្សាហកម្មរបស់ខ្លួនអោយល្អ ដោយធ្វើការ ដំឡើង ឬប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ ផ្តល់គំរូ រៀបចំ ឬ រក្សាទុកឯកសារ ហើយបញ្ជូនកំណត់ត្រា និងរបាយការណ៍ សម្រាប់ការត្រួតពិនិត្យ។

ទី៣៖ អាជ្ញាធរដែលស្ថិតក្រោមក្រសួងដែលពាក់ព័ន្ធ គឺមាន ដូចជាអាជ្ញាធរថ្នាក់ជាតិ ដែលមានក្រសួងបរិស្ថាន ក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន) និងក្រសួងមហាផ្ទៃ។

ទី៤៖ អ្នកផ្តល់សេវាប្រមូលសំរាម មានដូចជារដ្ឋាករស្វយ័ត គ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីខេត្ត និងក្រុមហ៊ុន ឯកជន (ក្រុមហ៊ុនសាំរ៉ុ ត្រេឌីង Mizuda Group Co., Ltd, and CINTRI (Cambodia)/Everbright (China) ។


រក្សាសិទ្ធិ:Thomas Cristofoletti/Ruom. Copyright©2018 Royal Holloway, University of London

## ដើម្បីអោយដំណោះស្រាយនោះមានប្រសិទ្ធិភាព តើយើងទាំងអស់គ្នាត្រូវមានភារកិច្ច និងកាតព្វកិច្ចអ្វីខ្លះ ?

- ចូលរួមផ្សព្វផ្សាយ និងកាត់បន្ថយការបញ្ចេញចោលនូវកាកសំណល់ផ្នែកជាតិពុលដែលប៉ះពាល់ ដល់បរិស្ថាន
- ចូលរួមបំផុសគំនិត ផ្សព្វផ្សាយទៅដល់អ្នកជុំវិញខ្លួន ដើម្បីផ្តួចផ្តើមនូវ ដំណោះស្រាយ តាមរយៈការបង្កើតគម្រោងផ្សព្វផ្សាយក្នុងសហគមន៍ឬការបង្កើននវានុវត្តន៍ដែលផ្តល់នូវ និរន្តរភាពដល់បរិស្ថាន
- ចូលរួមរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនូវរាល់ការចោលសំរាម ឬកាកសំណល់រឹងឧស្សាហកម្ម ដែលល្មើសនឹងច្បាប់ជាធរមាន

## ឯកសារយោង


1. រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣
2. ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
3. អនុក្រឹត្យលេខ៣៦ ស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩
4. រាជរដ្ឋាភិបាលកម្ពុជា, »គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥», ខែមីនា ២០១៥
5. Hanna Guy, "Waste Stream Mapping: Pathways from Key Suppliers to Landfill", Report-Cambodia, February-March 2021. (ឯកសារជាភាសាអង់គ្លេស)


## រៀបរៀងដោយនិស្សិត៖


កញ្ញា កែវ ហង្សបញ្ញា
កញ្ញា ភួង លាភហេង
កញ្ញា លី សុច័ន្ទថា
កញ្ញា សៅ ច័ន្ទណារ៉ា


## គាំទ្រដោយ៖


ELBBL English Language Based Bachelor of Law Program
RAOUL WALLENBERG INSTITUTE
ស៊ុយអែត Sverige
LAW CLINIC RULE - English Language Based Bachelor of Law (ELBBL) Program


ឯកសារខាងលើនេះ គឺជាតម្រូវការមួយសម្រាប់ការបញ្ចប់វគ្គជំនាញវិជ្ជាជីវៈច្បាប់ (Professional Legal Skills) នៃកម្មវិធីសិក្សានីតិសាស្ត្រជាភាសាអង់គ្លេស (ELBBL) របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) ដែលបានបង្កើតឡើងក្នុងគោលបំណងអប់រំ និងចែករំលែកចំណេះដឹងផ្នែកច្បាប់តែប៉ុណ្ណោះ ។ ពួកយើងស្វាគមន៍ក្នុងការទទួលនូវមតិសម្រាប់ធ្វើការកែលម្អ។